ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# របាយការណ៍សង្ខេបរបស់ ឯកឧត្តម អ៊ុច បូររិទ្ធ
# រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ
# ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងទិសដៅការងារ
# ឆ្នាំ២០២៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣

- **សូមគោរព ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង/ស្ថាប័ននានា**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
- **ភ្ញៀវកិត្តិយសទាំងអស់ជាទីរាប់អាន!**

១- ខ្ញុំមានសេចក្តីសោមនស្សរីករាយ និងមានកិត្តិយសបំផុត ដោយទទួលបានការអនុញ្ញាតពី ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ គោរពរាយការណ៍ជូនអំពីសមិទ្ធផលសំខាន់ៗដែលក្រសួងសម្រេចបានក្នុងឆ្នាំ២០២២ កន្លងទៅ។

២- ក្រោយពីអាក់ខានអស់រយៈពេលពីរឆ្នាំ ថ្ងៃនេះក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ (កបទ.សអ.) បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួង ដើម្បីដកស្រង់បទពិសោធន៍ការងារ ពិនិត្យពិភាក្សាអំពីសមិទ្ធផលដែលទទួលបាន និងបញ្ហាប្រឈម ក្នុងការអនុវត្តការងារអាទិភាពធំៗទាំង៥ និងកំណត់ទិសដៅអាទិភាពការងារបន្ត សម្រាប់ឆ្នាំ២០២៣។

៣- ឆ្នាំ២០២២ គឺជាឆ្នាំដែលពោរពេញទៅដោយការប្រឈមភូមិសាស្ត្រនយោបាយ និងសង្គម សេដ្ឋកិច្ចធំៗ បង្កឡើងដោយការប្រកួតប្រជែងកាន់តែខ្លាំងឡើង ស្មុគស្មាញឡើង រវាងមហាអំណាចធំៗ ការផ្ទុះឡើងនូវសង្គ្រាមនៅអឺរ៉ុប ដែលតិចណាស់នឹកស្មានដល់ ហើយដែលបានបង្កមហន្តរាយធ្ងន់ធ្ងរដល់ជីវិតមនុស្ស ហេដ្ឋារចនាសម្ព័ន្ធនានា ព្រមទាំងបង្កើតវិបត្តិស្បៀងនិងថាមពល ក្នុងពេលដែលពិភពលោកកំពុងងើបឡើងវិញដោយលំបាកពីផលប៉ះពាល់ពហុវិស័យដោយជំងឺរាតត្បាតកូវីដ-១៩។ ព្រមជាមួយនេះ ស្ថានភាពនៅឧបទ្វីបកូរ៉េ បន្តឱ្យមានការព្រួយបារម្ភ ដោយសារការបាញ់សាកល្បងកាំជ្រួច ក្នុងចំនួនច្រើនមិនធ្លាប់មានដោយកូរ៉េខាងជើង និងការឆ្លើយតបពីសហរដ្ឋអាមេរិក និងកូរ៉េខាងត្បូង ដោយការធ្វើសមយុទ្ធជាទ្រង់ទ្រាយធំ។ ស្ថានភាពនៅច្រកសមុទ្រតៃវ៉ាន់ ក៏ហក់ទៅកាន់កម្រិតធ្ងន់ធ្ងរ និងគ្រោះថ្នាក់ បន្ទាប់ពីប្រធានសភាអាមេរិកទៅបំពេញទស្សនកិច្ចផ្លូវការនៅលើកោះតៃវ៉ាន់។ ក្នុងពេលដែលស្ថានការណ៍នៅសមុទ្រចិនខាងត្បូង រក្សាបានភាពស្ងប់ស្ងៀមបង្គួរ ដោយសារការខិតខំរបស់ភាគី

ពាក់ព័ន្ធនានាក្នុងការចរចាឱ្យសម្រេចនូវក្រមប្រតិបត្តិ (COC) ដើម្បីជួយគ្រប់គ្រងជម្លោះ និងទំនាស់នានាដោយសន្តិវិធី នោះប្រទេសមីយ៉ាន់ម៉ា នៅតែកេចក្រចេញពីវិបត្តិនយោបាយ សន្តិសុខមិនរួច ដោយសារការតាំងចិត្តរបស់ភាគីជម្លោះក្នុងការយកឈ្នះតាមផ្លូវអាវុធ។

៤- ជាមួយនឹងវិបត្តិនយោបាយ យោធា ជាតិសាសន៍ ដ៏តាំងតឹងដែលមានស្រាប់ឬកំពុងធ្លាក់ចុះកាន់តែធ្ងន់ធ្ងរនៅតំបន់នានាផ្សេងទៀតនោះ បញ្ហាសន្តិសុខមិនប្រពៃណីផ្សេងទៀតដូចជាការប្រែប្រួលអាកាសធាតុ បញ្ហាជនភៀសខ្លួនអន្តោប្រវេសន៍ ឧក្រិដ្ឋកម្មឆ្លងដែន ភេរវកម្ម ។ល។ ក៏បានទាញយកមួយផ្នែកធំនៃពេលវេលា ថាមពល និងធនធានដែលចាំបាច់ ដើម្បីស្តារសេដ្ឋកិច្ចឡើងវិញពីមហន្តរាយនៃជំងឺកូវីដ-១៩។

៥- ឆ្នាំ ២០២២ ជាឆ្នាំដែលកម្ពុជាទទួលតួនាទីជាប្រធានប្តូរវេនរបស់អាស៊ានជាលើកទី ៣ ចាប់តាំងពីបានក្លាយជាសមាជិកនៃសហគមន៍នៅឆ្នាំ ១៩៩៩ មក។ ការពិត ឆ្នាំណាក៏អាស៊ានជួបប្រទះនឹងត្រូវដោះស្រាយការប្រឈមក្នុងកម្រិតនិងទម្រង់ផ្សេងៗគ្នា ប៉ុន្តែក្នុងប្រវត្តិសាស្ត្រ ៥៥ ឆ្នាំរបស់ខ្លួន អាស៊ានមិនដែលប្រឈមនិងបញ្ហាគ្រោះថ្នាក់ច្រើនបែបនេះ និងក្នុងពេលតែមួយដូចក្នុងឆ្នាំ ២០២២ នោះទេ។ ស្ថានការណ៍នេះ បានតម្រូវឱ្យថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកទាំងអស់នៃក្រសួងការបរទេសយើង ក្រោមការណែនាំជាប់ជាប្រចាំពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** បង្កើនមិនត្រឹមតែកិច្ចប្រឹងប្រែង ការអត់ធ្មត់ក្នុងការងារប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវប្រឹងប្រែងសំលៀងភាពវាងវៃ រក្សាការប្រុងប្រយ័ត្ន និងជំរុញឱ្យដល់កម្រិតខ្ពស់បំផុតនូវគ្រប់មធ្យោបាយការទូត ដើម្បីសម្រេចឱ្យបានជោគជ័យនូវការអនុវត្តនយោបាយការបរទេសដែលឯករាជ្យនិងផ្អែកលើច្បាប់ និងផ្អែកលើផលប្រយោជន៍គោលរបស់ជាតិនិងប្រជាជនយើង។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**

## I. លទ្ធផលសរុបការងារឆ្នាំ២០២២

៦- តទៅនេះ ខ្ញុំសូមគោរពរាយការណ៍ជូនពីលទ្ធផលសរុបការងារឆ្នាំ២០២២ ដែលផ្តោតលើការដ្ឋានធំៗទាំង៥ របស់ក្រសួងការបរទេសយើង ហើយដែលបានទទួលការគាំទ្រនិងលើកទឹកចិត្តពី **សម្តេចតេជោនាយករដ្ឋមន្ត្រី៖**

### **ភារៈទី១៖** ការការពារផលប្រយោជន៍ជាតិ ជាពិសេសការការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី

#### ១.១. ការការពារឯករាជ្យ អធិបតេយ្យ កិត្តិយស និងសេចក្តីថ្លៃថ្នូរជាតិ

- កម្ពុជាត្រូវបានបន្តយាយីដោយការចោទប្រកាន់ក្នុងចេតនានយោបាយ គ្មានមូលដ្ឋាន និងខ្វះភាពសត្យានុម័ត លើបញ្ហាសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ បញ្ហាមូលដ្ឋានយោធាបរទេសនៅតំបន់ឆ្នេរ និងបញ្ហាផ្សេងៗទៀតដែលប៉ះពាល់ដល់អធិបតេយ្យ ឯករាជ្យ អព្យាក្រឹតភាព សន្តិភាព ស្ថិរភាព

កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ជាតិ។ តបតនឹងការចោទប្រកាន់ទាំងនេះ ថ្នាក់ដឹកនាំជាច្រើន ជាពិសេស **សម្តេចតេជោនាយករដ្ឋមន្ត្រី ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** កបទ.សអ. និងស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជាប្រចាំអ.ស.ប. និងអង្គការអន្តរជាតិនានានៅទីក្រុងហ្សឺណែវបាន៖

- លើកជាប្រធានបទពិភាក្សា បកស្រាយពន្យល់ ក្នុងឱកាសជំនួបជាមួយមិត្តបរទេសជាច្រើនលើក
- ចេញសេចក្តីប្រកាសព័ត៌មាន សេចក្តីថ្លែងការណ៍អ្នកនាំពាក្យ ប្រតិកម្មឆ្លើយតប ចំនួន **៥១ លើក**
- ថ្លែងបទអន្តរាគមន៍សរុប ចំនួន **៧១ លើក** ក្នុងវេទិកាក្រុមប្រឹក្សាសិទ្ធិមនុស្ស និងធ្វើចលនាស្វែងរកការគាំទ្រជាមួយមិត្តបរទេស ចំនួន **៦០ប្រទេស** ក្នុងគោលបំណងបង្កើនសម្លេងវិជ្ជមានរបស់កម្ពុជាលើឆាកអន្តរជាតិ។ ជាលទ្ធផល នៅក្នុង «**កិច្ចសន្ទនាអន្តរកម្មជាមួយអ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា**» កាលពីខែតុលា ឆ្នាំ២០២២កន្លងទៅ ប្រទេសចំនួន ៣០ ក្នុងចំណោមប្រទេសចំនួន ៣៩ បានថ្លែងគាំទ្រចំពោះកិច្ចខិតខំប្រឹងប្រែង វឌ្ឍនភាព និងសមិទ្ធផលកម្ពុជា ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្សលើទិដ្ឋភាពជាច្រើន។

## ១.២ ការការពារបូរណភាពទឹកដីកម្ពុជា

- នៅក្នុងបុព្វហេតុការពារបូរណភាពទឹកដី និងដោះស្រាយបញ្ហាព្រំដែន ជាមួយប្រទេសជិតខាងឱ្យក្លាយទៅជាព្រំដែនសន្តិភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ កបទ.សអ. បានសហការជាមួយស្ថាប័នពាក់ព័ន្ធ៖
  - ធ្វើការតវ៉ាលើសកម្មភាពបំពាន នៅចំណុចព្រំដែន ឬតំបន់មិនទាន់បានឯកភាពគ្នា ជាមួយប្រទេសជិតខាង ចំនួន **៤ លើក**
  - សម្របសម្រួលកិច្ចចរចាលើសន្ធិសញ្ញាកំណត់ព្រំដែន កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងច្រកទ្វារព្រំដែនគោក និងរៀបចំដំឡើងកម្រិតច្រកទ្វារអន្តរជាតិជាដើម។ ក្នុងនោះ ជាមួយឡាវ បានសម្រេចនូវសន្ធិសញ្ញាព្រំដែន ៨៦% ដែល**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានចុះហត្ថលេខានៅថ្ងៃទី១៣ ខែកុម្ភៈ។ ក្រៅពីនេះ កបទ.សអ. បាន និងកំពុងខិតខំសម្របសម្រួលការចរចាព្រំដែនជាមួយភាគីថៃ និងវៀតណាមបន្តទៀត។

## ១.៣ ការការពារផលប្រយោជន៍ពលរដ្ឋខ្មែរនៅបរទេស

- កបទ.សអ. បានផ្តល់ការគាំទ្រ គាំពារ ជួយសង្គ្រោះ និងសម្របសម្រួលមាតុភូមិនិវត្តន៍ដល់ពលរដ្ឋខ្មែរដែលរងគ្រោះដោយការរំលោភសិទ្ធិសេរីភាពនៅបរទេស និង អំពើជួញដូរមនុស្ស ចំនួន ៧ ៩៥៣ នាក់ ពីប្រទេសថៃ ឡាវ វៀតណាម ម៉ាឡេស៊ី ចិន ឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា សិង្ហបុរី។ លើសពីនេះ ស្ថានតំណាងកម្ពុជាប្រចាំនៅបរទេស បានយកចិត្តទុកដាក់ខ្ពស់ក្នុងការប្រាស្រ័យទាក់ទងជាមួយពលរដ្ឋកម្ពុជារស់នៅបរទេសមានជាអាទិ៍ អាមេរិក បារាំង អឺរ៉ុប និងអូស្ត្រាលី ក៏ដូចជាសម្របសម្រួល

ដល់សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ សិស្ស/និស្សិត ពលករ ដែលកំពុងរស់នៅ ធ្វើការ និងសិក្សានៅបរទេស រួមមានការផ្តល់សេវារដ្ឋបាល សេវាកុងស៊ុល និងការឧបត្ថម្ភគាំពារផ្សេងៗ។

## **ភារៈទី២៖ ការអនុវត្តគោលនយោបាយការបរទេសឯករាជ្យផ្អែកលើច្បាប់អន្តរជាតិប្រកបដោយភាពបត់បែន វាងវៃ តបតទៅនឹងសម្ពាធភូមិសាស្ត្រនយោបាយ**

ឆ្នាំ ២០២២ ជាឆ្នាំដែលកម្ពុជាបានទទួលជោគជ័យយ៉ាងត្រចះត្រចង់ក្នុងវិស័យការទូត ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី៖

### ២.១ ទំនាក់ទំនងទ្វេភាគី

- កម្ពុជាបានបន្តពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគី តាមរយៈសកម្មភាពរបស់ស្ថានទូត/ស្ថានតំណាងអចិន្ត្រៃយ៍កម្ពុជានៅបរទេសចំនួន ៣១ ស្ថានអគ្គកុងស៊ុលកម្ពុជានៅបរទេសចំនួន ១២ កុងស៊ុលកិត្តិយសកម្ពុជានៅបរទេស ចំនួន ២៦ និងមន្ត្រីការទូតដែលកំពុងបំពេញបេសកកម្មនៅបរទេសសរុបចំនួន ២០២ នាក់។

- នៅក្នុងទិសដៅរួមចំណែកជួយស្វែងរកដំណោះស្រាយសន្តិភាព សន្តិសុខ និងស្ថិរភាពក្នុងតំបន់ ក៏ដូចជាដើម្បីពង្រឹងបន្ថែមចំណងមិត្តភាពនិងកិច្ចសហប្រតិបត្តិការល្អប្រសើរទ្វេភាគី **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានបំពេញទស្សនកិច្ចការងារ និងទស្សនកិច្ចផ្លូវការ នៅប្រទេសមីយ៉ាន់ម៉ា បារាំង គុយបា ជប៉ុន សាធារណរដ្ឋកូរ៉េ និង វៀតណាម។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបំពេញទស្សនកិច្ចផ្លូវការ និងការងារ នៅប្រទេសបារាំង អាល្លឺម៉ង់ និងតួកគី និងបានអញ្ជើញចូលរួមកិច្ចប្រជុំសំខាន់ៗផ្សេងទៀត ដូចយ៉ាង ជាមួយគណៈកម្មការអឺរ៉ុប នៅទីក្រុងព្រុចសែល កិច្ចប្រជុំពិគ្រោះយោបល់បើកចំហស្តីពីបញ្ហាមីយ៉ាន់ម៉ា នៅទីក្រុងបាងកក កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង (MLC) លើកទី៧ នៅទីក្រុងបាហ្គាន ប្រទេសមីយ៉ាន់ម៉ា ចូលរួមវេទិកាថ្នាក់រដ្ឋមន្ត្រីស្តីពីកិច្ចសហប្រតិបត្តិការក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក នៅទីក្រុងប៉ារីស កិច្ចប្រជុំពិសេសថ្នាក់រដ្ឋមន្ត្រីអាស៊ាន-ឥណ្ឌា នៅទីក្រុងញូវដេលី ធ្វើជាសហប្រធានកិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការបរទេសអាស៊ានអំពីបញ្ហាមីយ៉ាន់ម៉ា នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី។ល។ ទន្ទឹមនេះ កម្ពុជាក៏បានស្វាគមន៍ទស្សនកិច្ចផ្លូវរដ្ឋ និងផ្លូវការរបស់ថ្នាក់ដឹកនាំបរទេស ចំនួន **១១** មកពីប្រទេសចិន ជប៉ុន វៀតណាម ម៉ាឡេស៊ី សិង្ហបុរី ទីម័រខាងកើត ព្រុយណេ ឥណ្ឌូណេស៊ី អារ៉ាប៊ីសាអូឌីត បង់ក្លាដែស និងគុយបា។

- ទំនាក់ទំនងកម្ពុជានិងប្រទេសជិតខាងបានបន្តល្អប្រសើរ ជាមួយនឹងការផ្លាស់ប្តូរទស្សនកិច្ច និងជំនួបសន្ទនារវាងថ្នាក់ដឹកនាំជាញឹកញាប់។ ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគី ជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិកជាទូទៅ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ តាមរយៈការផ្លាស់ប្តូរ

ទស្សនកិច្ច និងជំនួបទ្វេភាគីជាច្រើនលើកក្នុងកម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់ ជាពិសេសសន្ទុះកំណើន ការផ្លាស់ប្តូរពាណិជ្ជកម្ម ទេសចរណ៍ និងវិនិយោគ បន្ទាប់ពីវិបត្តិនៃជំងឺរាតត្បាតសកល។ ក្នុងនោះ ទំនាក់ទំនងទ្វេភាគីគួរឱ្យកត់សម្គាល់៖ (១) **ជាមួយចិន** នៅបន្តរក្សាបាននូវ«**សហប្រតិបត្តិការក្នុងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ពង្រឹងមិត្តភាពដែកថែប និងកសាងសហគមន៍វាសនារួមជាមួយគ្នា**»ជាមួយនឹងទំនុកចិត្តនយោបាយខ្ពស់ និងឈរលើកិច្ចសហប្រតិបត្តិការជិតរឹងមាំលើគ្រប់វិស័យ (២) **ជាមួយជប៉ុន** បានបន្តក្នុងភាពជិតស្និទ្ធ ដោយក្នុងឆ្នាំ២០២២ នាយករដ្ឋមន្ត្រីទាំងពីរបានជួបសន្ទនាគ្នាដោយផ្ទាល់រហូតដល់ទៅ ៤លើក។ ក្នុងជំនួបចុងក្រោយរវាង **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងនាយករដ្ឋមន្ត្រី Kishida Fumio ភាគីទាំងពីរបានសម្រេចដំឡើងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីដល់កម្រិត «**ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ**» នៅឆ្នាំ២០២៣នេះជាឆ្នាំដែលប្រទេសទាំងពីរអបអរសាទរខួប ៧០ ឆ្នាំ នៃការបង្កើតទំនាក់ទំនងការទូតជាមួយគ្នា (៣) ជាមួយវៀតណាម និងឡាវ ទំនាក់ទំនងត្រូវបានបន្តពង្រឹងនិងពង្រីកថែមទៀតជាលំដាប់ពិសេសតាមរយៈជំនួបអាហារពេលព្រឹកការងាររវាងនាយករដ្ឋមន្ត្រីទាំងបី កម្ពុជា វៀតណាម និងឡាវ នៅទីក្រុងព្រុចសែល កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២។

- ការប្រកាន់ជំហរយ៉ាងត្រឹមត្រូវ និងម៉ឺងម៉ាត់របស់កម្ពុជា គាំទ្រគោលបំណង និងគោលការណ៍នៃធម្មនុញ្ញអ.ស.ប. ក្នុងសង្គ្រាមនៅអ៊ុយក្រែន បានកែសម្រួលយ៉ាងខ្លាំងនូវទំនាក់ទំនងរវាងកម្ពុជាជាមួយបណ្តាប្រទេសបស្ចិមលោក រួមទាំងស.រ.អា.ផងដែរ ដោយបង្ហាញឱ្យឃើញច្បាស់នូវការប្រកាន់នយោបាយការបរទេសឯករាជ្យផ្អែកលើច្បាប់អន្តរជាតិ។ ការកែសម្រួលនេះបានស្តែងឡើងតាមរយៈការអញ្ជើញមកចូលរួមរបស់លោកប្រធានាធិបតីអាមេរិក Joe Biden និង លោករដ្ឋមន្ត្រីការបរទេស Antony Bliken ក្នុងកិច្ចប្រជុំកំពូល និងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសពាក់ព័ន្ធនឹងអាស៊ាន និងគណៈប្រតិភូចម្រុះព្រឹទ្ធសភានិងសភាអាមេរិក និងឥស្សរជននានា ដែលបានមកបំពេញទស្សនកិច្ចជាបន្តបន្ទាប់នៅកម្ពុជា។ ជាមួយគ្នានេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានដឹកនាំគណៈប្រតិភូធ្វើទស្សនកិច្ច និងពិសាអាហារពេលល្ងាច ជាលើកដំបូង នៅស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា កាលពីចុងឆ្នាំ២០២២ កន្លងទៅ ចាប់តាំងពីប្រទេសទាំងពីរភ្ជាប់ទំនាក់ទំនងការទូតកាលពីឆ្នាំ១៩៥០ មក។ ដោយឡែក **សម្តេចតេជោនាយករដ្ឋមន្ត្រី** ត្រូវបានលោកប្រធានាធិបតីបារាំង Emmanuel Macron អញ្ជើញបំពេញទស្សនកិច្ចការងារ ដោយរៀបចំបាយការងារនៅវិមាន Élysée កាលពីថ្ងៃទី១៣ ខែធ្នូ។ ក្នុងឱកាសនោះ លោកប្រធានាធិបតីបានផ្តល់ការទទួលស្វាគមន៍យ៉ាងកក់ក្តៅ ហើយកិច្ចពិភាក្សារវាងថ្នាក់ដឹកនាំកំពូលទាំងពីរបានប្រព្រឹត្តទៅប្រកបដោយភាពជិតស្និទ្ធ ស្មោះត្រង់ និងការទុកចិត្តគ្នាទៅវិញទៅមក។ ក្រៅពីនេះ ក្នុងឱកាសអញ្ជើញជាសហប្រធានកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-សហភាពអឺរ៉ុប នៅទីក្រុងព្រុចសែល កាលពីថ្ងៃទី១៤ ខែធ្នូ កន្លងទៅ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានជួបទ្វេភាគីជាមួយឥស្សរជនបរទេសមួយចំនួនទៀតរួមមាន អធិការបតីអាល្លឺម៉ង់

Olaf Scholz នាយករដ្ឋមន្ត្រីហូឡង់ Mark Rutte និងនាយករដ្ឋមន្ត្រីហ្វាំងឡង់ Sanna Marin។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានជួបជាមួយប្រធានក្រុមប្រឹក្សាអឺរ៉ុប Charles Michel ចំនួន ២ ដង នៅជប៉ុន និងនៅកម្ពុជា។

- ជាមួយគ្នានេះ កបទ.សអ. ក៏បានខិតខំប្រឹងប្រែងក្នុងការពង្រឹងពង្រីកចំណងមិត្តភាពនិងកិច្ចសហប្រតិបត្តិការល្អប្រសើរ ជាមួយប្រទេសជាមិត្ត តាមរយៈយន្តការកិច្ចពិគ្រោះយោបល់ទ្វេភាគីទាំង១១ និងកំពុងបន្តរិះរកមធ្យោបាយ និងលទ្ធភាពធ្វើពិពិធកម្មដៃគូទំនាក់ទំនងអន្តរជាតិតាមរយៈយន្តការនេះជាមួយបណ្តាប្រទេសផ្សេងទៀតនៅតំបន់អាស៊ី អូសេអានី អឺរ៉ុបកណ្តាល និងខាងកើត អាមេរិកឡាទីន និងអាមេរិកកណ្តាល។

## ២.២ ទំនាក់ទំនងពហុភាគី

- ក្នុងក្របខ័ណ្ឌអាស៊ាន កម្ពុជាទទួលជោគជ័យយ៉ាងត្រចះត្រចង់ និងទទួលបានការកោតសរសើរយ៉ាងខ្លាំងពីសំណាក់សហគមន៍អន្តរជាតិ ចំពោះភាពប៉ិនប្រសប់ បត់បែន និងវាងវៃ នៅក្នុងការដឹកនាំកិច្ចប្រជុំពេញមួយឆ្នាំក្នុងតួនាទីជាប្រធានប្តូរវេនអាស៊ាន រួមទាំងតួនាទីដ៏សកម្មរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិក្នុងតួនាទីជាប្រេសិតពិសេសរបស់ប្រធានអាស៊ានក្នុងដំណើរការស្វែងរកដំណោះស្រាយដើម្បីជួយមីយ៉ាន់ម៉ាត្រឡប់ទៅរកប្រក្រតីភាពឡើងវិញ។ ជាក់ស្តែង កម្ពុជាទទួលបានលទ្ធផលគួរជាទីមោទនៈនៅក្នុងការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន និងកិច្ចប្រជុំរដ្ឋមន្ត្រីពាក់ព័ន្ធ ដោយបានចេញទាន់ពេលវេលានូវសេចក្តីប្រកាសរួមរបស់រដ្ឋមន្ត្រីការបរទេសអាស៊ាន (Joint Communiqué) ដែលជាឯកសារយោងដ៏សំខាន់បំផុតមួយសម្រាប់ព្រាងឯកសារសមិទ្ធផលដទៃផ្សេងទៀត។ សរុបមក កិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ សម្រេចលទ្ធផលលើសពីការរំពឹងមួយចំនួន រួមមាន៖ (១) ការសម្រេចបានឯកសារ១០១ ក្នុងចំណោមឯកសារសមិទ្ធផលដទៃទៀត ដែលត្រូវបានអនុម័ត និងកត់សម្គាល់ដោយថ្នាក់ដឹកនាំកំពូលអាស៊ាន (២) ការបន្ថែមសមាជិកថ្មីក្នុងសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) ចំនួន៧ ក្នុងមួយឆ្នាំ ដែលនេះ ច្រើនជាងឆ្នាំណាៗទាំងអស់ (៣) ការពង្រីកដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយជាមួយប្រទេស ចំនួន២ និង (៤) ការសម្រេចទទួលជាគោលការណ៍ឱ្យទីម័រខាងកើតចូលជាសមាជិកអាស៊ានទី១១។ បន្ថែមលើកិច្ចប្រជុំអាស៊ានដែលមានជាទៀងទាត់ កម្ពុជាក៏បានធ្វើជាសហប្រធាន នៃកិច្ចប្រជុំកំពូលពិសេសអាស៊ាន-សហរដ្ឋអាមេរិក នៅទីក្រុងវ៉ាស៊ីនតោន និងកិច្ចប្រជុំរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-សហភាពអឺរ៉ុប នៅទីក្រុងព្រុចសែល ប្រកបដោយភាពជោគជ័យគាប់ប្រសើរ។

- ក្រៅពីនេះ កម្ពុជាក៏បានបន្តចូលរួមយ៉ាងសកម្មក្នុងយន្តការពហុភាគីដទៃទៀត ដើម្បីចូលរួមជាផ្នែកមួយក្នុងការកសាងសហគមន៍ នៅក្នុងតំបន់ និងសកលលោក ប្រកបដោយសន្តិភាព សន្តិសុខ

និងវិបុលភាព ដូចជាយន្តការកិច្ចសហប្រតិបត្តិការមេគង្គ, Francophonie, NAM, CICA, SCO, ADM, BOAO, CLV, CLMV ជាដើម។

## ភារៈទារទី៣៖ ការចូលរួមក្នុងបុព្វហេតុសន្តិភាព ស្ថិរភាព និងដំណោះស្រាយបញ្ហាប្រឈមនានានៅក្នុងពិភពលោក

- ពីឆ្នាំ២០០៦ រហូតដល់ពេលបច្ចុប្បន្ន កម្ពុជាបានបញ្ជូនកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាពក្រោមឆត្រអង្គការសហប្រជាជាតិ (អ.ស.ប.) សរុបចំនួន ៨ ៩៥១នាក់ (ស្ត្រី៖ ៦៩២នាក់) ទៅកាន់ប្រទេសចំនួន ៩ រួមមាន៖ ស៊ូដង់ ស៊ូដង់ខាងត្បូង ឆាដ សាធារណរដ្ឋអាហ្វ្រិកកណ្តាល លីបង់ ស៊ីប ស៊ីរី ម៉ាលី និងយេម៉ែន។ តាមការវាយតម្លៃរបស់អ.ស.ប. កម្ពុជាជាប់ចំណាត់ថ្នាក់លេខ ២៨ ក្នុងចំណាមប្រទេសចំនួន ១២២ និងចំណាត់ថ្នាក់លេខ ៣ ក្នុងតំបន់អាស៊ាន (បន្ទាប់ពីឥណ្ឌូណេស៊ី និងម៉ាឡេស៊ី)ក្នុងការចូលរួមបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមនេះ។ ដោយឡែក ក្នុងការបញ្ជូនកងកម្លាំងជានារី កម្ពុជាទទួលបានចំណាត់ថ្នាក់លេខ ១៣ ទូទាំងពិភពលោក និងចំណាត់ថ្នាក់លេខ ២ ក្នុងចំណោមប្រទេសអាស៊ានបន្ទាប់ពីឥណ្ឌូណេស៊ី។
- នៅក្នុងសំណុំរឿងសង្គ្រាមនៅអ៊ុយក្រែន ក្នុងស្មារតីគាំទ្រយ៉ាងម៉ឺងម៉ាត់គោលការណ៍ច្បាប់អន្តរជាតិ គោលបំណងនិងគោលការណ៍នៃធម្មនុញ្ញអ.ស.ប. និងការពារសន្តិភាពក្នុងពិភពលោក កម្ពុជាបានចូលរួមជាសហស្ថាបនិកគាំទ្រលើ សេចក្តីសម្រេចចិត្តមហាសន្និបាតអ.ស.ប ចំនួន ៣ ស្តីពី៖ (១) បូរណភាពទឹកដីនៃប្រទេសអ៊ុយក្រែន៖ ការពារគោលការណ៍នៃធម្មនុញ្ញអ.ស.ប. (២) ផលវិបាកមនុស្សធម៌នៃការឈ្លានពានប្រឆាំងនឹងអ៊ុយក្រែន និង (៣) ការឈ្លានពានអ៊ុយក្រែន។ ក្រៅពីនេះ កម្ពុជាបោះឆ្នោតអនុប្បវាទលើសេចក្តីព្រាងសេចក្តីសម្រេចចិត្ត ចំនួន ២ ស្តីពី ៖ (១) ការព្យួរសិទ្ធិសមាជិកភាពសហព័ន្ធរុស្ស៊ីនៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្សអ.ស.ប. និង (២) ការបន្តផ្តល់សំណងបណ្តាលមកពីការឈ្លានពាននៅអ៊ុយក្រែន។ ទន្ទឹមនេះ កម្ពុជាបានចូលរួមយ៉ាងសកម្មជាមួយសហគមន៍អន្តរជាតិ ក្នុងការដោះស្រាយបញ្ហាប្រឈមសកលនានា ដែលមានជាអាទិ៍ការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ការប្រែប្រួលអាកាសធាតុ ជំងឺឆ្លង បញ្ហាអន្តោប្រវេសន៍ ។ល។ ដើម្បីបុព្វហេតុសន្តិភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់ និងពិភពលោក។

## ភារៈទារទី៤៖ ការអនុវត្តការងារការទូតសេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍ ដើម្បីលើកស្ទួយសេដ្ឋកិច្ច

- នៅក្នុងកិច្ចការការទូតសេដ្ឋកិច្ច កបទ.សអ. និងស្ថានតំណាងកម្ពុជានៅបរទេសបាន៖ (១) រៀបចំវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយការយល់ដឹងពីសក្តានុពលវិនិយោគ និងទេសចរណ៍ដល់ថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងទាំងក្នុង និងក្រៅប្រទេស (២) រៀបចំជំនួបធុរកិច្ច ដើម្បីផ្សព្វផ្សាយគៀរគរវិនិយោគទុនបរទេស ចំនួន ៥ លើក (៣) បង្កើត «**ផ្ទះបាយអង្គរ**» សម្រាប់បណ្តុះបណ្តាល និងផ្សព្វផ្សាយ

កិត្តិនាមមុខម្ហូបខ្មែរ និង(៤) ពិភាក្សាជាមួយតំណាងសហគ្រាសបរទេស ក្នុងគោលបំណងផ្សព្វផ្សាយ និងកៀរគរទុនវិនិយោគ ភ្ញៀវទេសចរណ៍អន្តរជាតិ និងពង្រីកទីផ្សារផលិតផលទំនិញកម្ពុជា។ បន្ថែមលើនេះ សៀវភៅមុខម្ហូប «**គេហដ្ឋានដែលស្នាដៃម្ហូបខ្មែរ** /The Taste of Angkor» ក៏បានឈ្នះពានរង្វាន់ចំនួនពីរបន្ថែមទៀតនៅក្នុងសន្និសីទម្ហូបអាហារអន្តរជាតិនៅប្រទេសស៊ុយអែត រួមមានពានរង្វាន់៖ «**សៀវភៅម្ហូបអាស៊ីដ៏ល្អដាច់គេ**» និង «**សៀវភៅម្ហូបឆ្នើមដែលរៀបរៀងដោយថ្នាក់ដឹកនាំនៃរដ្ឋ**» ។

## អាទិភាពទី៥៖ ការបន្តការដ្ឋានកំណែទម្រង់ស្ថាប័ននៅក្នុងក្រសួង ដើម្បីរៀបចំអង្គភាពការទូតប្រកបដោយវិជ្ជាជីវៈ ស្នេហាជាតិ សកម្ម និងមានសមត្ថភាព

- ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារឱ្យបានស្របតាមទំហំនៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អប្រសើររវាងកម្ពុជា និងបណ្តាប្រទេសជាមិត្ត និងការវិវត្តនៃសភាពការណ៍ពិភពលោក កបទ.សអ. បានបើកវគ្គបណ្តុះបណ្តាលមន្ត្រីក្រសួង និងបញ្ជូនទៅចូលរួមវគ្គខាងក្រៅ សរុបចំនួន ៣៣ លើក ដែលមានសរុបចំនួន ៩៧៣ នាក់ (ក្រៅប្រទេស ២៩ នាក់)។ ដោយឡែក វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិបានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ៣០ លើក ដែលមានសិក្ខាកាមសរុបចំនួន ៨៧៩ នាក់ និងបានចុះអនុស្សរណៈយោគយល់គ្នា សរុបចំនួន ៦ ជាមួយវិទ្យាស្ថានចក្ខុវិស័យអាស៊ី និងវិទ្យាស្ថានអន្តរជាតិនៃប្រទេសចិន បង់ក្លាដែស គុយបា និងប្រេស៊ីល ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការបណ្តុះបណ្តាលក្នុងវិស័យការទូត។
- ក្រសួងបានលើកសំណើ និងទទួលបានការឯកភាពជាគោលការណ៍ពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** បំបែកពីរអគ្គនាយកដ្ឋានតំបន់ មានគម្រោងជ្រើសរើសមន្ត្រីការទូតបន្ថែម សុំដំឡើងប្រាក់រង្វាន់ពី ១០% ទៅ ២០% និងបានអនុវត្តគោលការណ៍គុណាធិបតេយ្យ (Meritocracy) ព្រមទាំងបានរៀបចំជាប្រចាំនូវរបបប្រជុំវិភាគព័ត៌មាន ២ លើក ក្នុងមួយសប្តាហ៍។

### ឯកឧត្តម លោកជំទាវ លោក លោកស្រី

៧- ជោគជ័យដ៏ត្រចះត្រចង់នៅក្នុងវិស័យការទូតដូចបានរៀបរាប់ជូនខាងលើនេះ ជាលទ្ធផលនៃការចង្អុលបង្ហាញដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលជាអគ្គមគ្គុទេសការទូតដ៏ឆ្នើម និងកំពូល និងការដឹកនាំគ្រប់គ្រងដ៏វាងវៃ ប៉ិនប្រសប់ របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាមួយនិងភាពអំណត់អត់ធន់តស៊ូព្យាយាម និងការប្តេជ្ញាចិត្តមិនរុញរារបស់ថ្នាក់ដឹកនាំ និងមន្ត្រី នៅគ្រប់ជាន់ថ្នាក់នៃ កបទ.សអ.។

## II. ទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

៨- នៅក្នុងឆ្នាំ២០២៣ ពិភពលោកត្រូវបានព្យាករណ៍ថានឹងបន្តវិវត្តក្នុងភាពមិនប្រាកដប្រជា ស្មុគស្មាញ និងពិបាកប៉ានស្មានបំផុត បង្កឡើងដោយបញ្ហាក្ដៅៗជាច្រើន រួមមាន៖ (១) ការបន្តប្រណាំងប្រជែងខាងភូមិសាស្ត្រនយោបាយនិងយុទ្ធសាស្ត្រ កាន់តែស្រួចស្រាល់របស់មហាអំណាច ជាពិសេសក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក (២) ការបន្តអូសបន្លាយនៃសង្គ្រាមនៅអ៊ុយក្រែនជាមួយនឹងហានិភ័យកាន់តែធំឡើងនៃការរាលដាល និងការប្រើប្រាស់អាវុធនុយក្លេអ៊ែរ (៣) ការគំរាមកំហែងអាវុធនុយក្លេអ៊ែរ (៤) វិបត្តិក្នុងតំបន់ និងក្រៅតំបន់ ដែលកាន់តែរអិលទៅរកចំណុចគ្រោះថ្នាក់ និងបញ្ហាកាន់តែស្មុគស្មាញពាក់ព័ន្ធនឹងសន្តិសុខប្រពៃណី និងមិនប្រពៃណីនានា និង (៥) បញ្ហាអតិផរណា និងការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក។

៩- ស្ថិតក្នុងបរិការណ៍ដ៏គ្រោះថ្នាក់បែបនេះ កម្ពុជានឹងពង្រឹងការអនុវត្តនយោបាយការបរទេសឯករាជ្យផ្អែកលើច្បាប់អន្តរជាតិ ដោយបន្តការងារការទូតបុរេសកម្ម វាងវៃ និងបត់បែនក្នុងការពង្រឹងទំនាក់ទំនងជាមួយមិត្តចាស់ បង្កើនទំនាក់ទំនងជាមួយមិត្តថ្មី ស្របតាមការវិវឌ្ឍសភាពការណ៍ភូមិសាស្ត្រនយោបាយតំបន់ និងពិភពលោក។ យើងនឹងបន្តប្ដេជ្ញាការពារនូវផលប្រយោជន៍ស្នូលរបស់ជាតិ ពោលគឺការពារ អធិបតេយ្យ បូរណភាពទឹកដី និងឯករាជ្យភាពកម្ពុជា ការពារសន្តិភាព ស្ថិរភាពក្នុងប្រទេសដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម តាមផែនការយុទ្ធសាស្ត្រជាតិ។ កបទ.សអ. នឹងបន្តខិតខំចូលរួមក្នុងការកៀរគរទុនវិនិយោគបរទេស ភ្ញៀវទេសចរណ៍ និងផ្សព្វផ្សាយពង្រីកទីផ្សារថ្មីដើម្បីជំរុញផលិតកម្មក្នុងស្រុក។ បន្ថែមពីនេះ កបទ.សអ.នឹងបន្តអនុវត្តការទូតវប្បធម៌ រួមមានការផ្សព្វផ្សាយអំពីវប្បធម៌ អរិយធម៌ សិល្បៈ និងម្ហូបអាហារ ក្នុងស្មារតីបង្កើត និងបង្កើនអំណាចស្រទន់ និងការស្គាល់កម្ពុជាលើឆាកអន្តរជាតិ។

១០- ការពិភាក្សាក្នុងរយៈពេល ២ ថ្ងៃនេះ ព្រមជាមួយនឹងអនុសាសន៍ដ៏ខ្ពង់ខ្ពស់ប្រកបដោយបញ្ញាញាណ វាងវៃ និងគតិបណ្ឌិតរបស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** នឹងអនុញ្ញាតឱ្យយើងរៀបចំចងក្រងទិសដៅការងារសម្រាប់កបទ.សអ. ឆ្នាំ២០២៣ ដោយម៉ត់ចត់ លំអិត គ្រប់ជ្រុងជ្រោយ និងស៊ីជម្រៅ។

១១- ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី នៃអង្គសន្និបាតទាំងមូល ចំពោះការយកចិត្តទុកដាក់ស្ដាប់នូវសេចក្ដីរាយការណ៍នេះ៕

**សូមអរគុណ!**